ក្រសួងការពារជាតិ

**សូមគោរពជូន**

**សម្តេចក្រឡាហោម ស ខេង អនុប្រធានគណបក្សប្រជាជនកម្ពុជា**

**និងជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម** អនុប្រធានគណបក្សប្រជាជនកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់!

ជាបឋម តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងក្នុងនាមខ្ញុំនិងភរិយាខ្ញុំ ព្រមទាំងសមាជិក សមាជិកា ក្រុមការងារទាំងអស់ សូមសម្តែងនូវមនោសញ្ចេតនា សោមនស្សរីករាយ និងអបអរសាទរយ៉ាងកក់ក្តៅបំផុតចំពោះ **សម្តេចក្រឡាហោម** ព្រមទាំង **លោកជំទាវ** និងក្រុមគ្រួសារ **សម្តេច** ក្នុងឱកាសដ៏ឧត្តុង្គឧត្តមថ្លៃថ្លាបំផុត ដែលសមាជិក សមាជិកា អង្គសន្និបាតគណៈកម្មាធិការកណ្តាលលើកទី៣៨ អាណត្តិទី៥ គណបក្សប្រជាជនកម្ពុជា បោះឆ្នោតជាឯកច្ឆន្ទជ្រើសតាំង **សម្តេច** ជា **អនុប្រធានគណបក្សប្រជាជនកម្ពុជា** នាថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០១៥ ។

ការបោះឆ្នោតជ្រើសតាំង **សម្តេចក្រឡាហោម ជាអនុប្រធានគណបក្សប្រជាជនកម្ពុជា** ពិតជាឆ្លុះបញ្ចាំងឲ្យឃើញពីសមត្ថភាព ប្រជាប្រិយភាព និងភាពជាអ្នកដឹកនាំស័ក្តិសមទៅនឹងគុណបំណាច់ និងស្នាដៃដ៏ធំធេងរបស់ **សម្តេច** ដែលបានលះបង់កម្លាំងកាយ-ចិត្តធ្វើពលិកម្ម គ្រប់បែបយ៉ាងដើម្បីបុព្វហេតុបំរើឧត្តមប្រយោជន៍ជាតិ មាតុភូមិ និងប្រជាពលរដ្ឋ ។

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ឧត្តុង្គឧត្តម ប្រពៃថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវការ គោរព កោតសរសើរចំពោះ **សម្តេច អនុប្រធានគណបក្សប្រជាជនកម្ពុជា** ជាឥស្សរៈជនដ៏ឆ្នើមមួយរូប ដែលបានចូលរួមចលនារំដោះប្រទេស ឲ្យរួចផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ព្រមទាំងសកម្មរួមចំណែកស្តារនិងអភិវឌ្ឍន៍ប្រទេសឲ្យមានការរីកចម្រើនលើ គ្រប់វិស័យ ជាពិសេសនៅក្នុងតួនាទីជាថ្នាក់ដឹកនាំក្នុងស្ថាប័នរាជរដ្ឋាភិបាល **សម្តេច** គឺជាឥស្សរៈជនឆ្នើមនិងសកម្មក្នុងការ ផ្សះផ្សាបង្រួបបង្រួមជាតិ ដើម្បីសន្តិភាព វឌ្ឍនៈភាពជាតិ ថែរក្សាការពាររឹងមាំនូវសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព ស្ថិរភាព សង្គមជាតិប្រកបដោយនិរន្តរភាព។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមប្រសិទ្ធិពរជ័យ ជូនចំពោះ **សម្តេច អនុប្រធានគណបក្សប្រជាជនកម្ពុជា** និង**លោកជំទាវ** ព្រមទាំងក្រុមគ្រួសារ សូមប្រកបដោយ ពុទ្ធពរទាំង ៤ប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអនុប្រធាន** មេត្តាទទួលនូវការគោរពស្រឡាញ់ ដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាសមាជិក**

**គណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា**

**ទៀ បាញ់**